# មជ្ឈមណ្ឌលភីឌីភី

# PDP-Center

## គោលនយោបាយបុគ្គលិក
## របស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព

### ប្រការ ១-គោលបំណង

គោលនយោបាយបុគ្គលិករបស់ មជ្ឈមណ្ឌល ភី ឌី ភី មានគោលបំណងដើម្បីធានាបាននូវសេចក្តីថ្លៃថ្នូរ, តម្លាភាព, ការជឿទុកចិត្ត និងការទទួលខុសត្រូវ ។ គោលនយោបាយនេះបង្កើតឡើងដើម្បីជាជំនួយអោយបុគ្គលិកទាំងអស់យកទៅប្រតិបត្តិដោយផ្ទាល់ក្នុងការបំពេញការងាររបស់ខ្លួនអោយទទួលបានជោគជ័យនិងមានប្រសិទ្ធភាពខ្ពស់ ។

### ប្រការ ២-ជំហរនយោបាយ

មជ្ឈមណ្ឌលភី ឌី ភី ជាអង្គការមិនមែនរដ្ឋាភិបាល អព្យាក្រឹត្យ ពីគណបក្សនយោបាយ និង រដ្ឋាភិបាល។ ដូចនេះបុគ្គលិក, អ្នកស្ម័គ្រចិត្ត ឬអ្នកជំនាញការ របស់ មជ្ឈមណ្ឌលភី ឌី ភី មិនត្រូវចូលរួមធ្វើសកម្មភាពនយោបាយ ក្នុងនាមមជ្ឈមណ្ឌល ភី ឌី ភី ដែលនាំអោយប៉ះពាល់ដល់ជំហររបស់ មជ្ឈមណ្ឌលភី ឌី ភី ជាដាច់ខាត ។

### ប្រការ ៣-ម៉ោងធ្វើការជាផ្លូវការ

ក្នុង១ សប្តាហ៍ធ្វើការ ៥ ថ្ងៃ ពីថ្ងៃថ្ងៃច័ន្ទ ដល់ថ្ងៃ សុក្រ

- ព្រឹកម៉ោង ៧:៣០- ១២:០០នាទី ហើយរយ:ពេលសំរាកគឺចន្លោះពី៩:៤៥ ទៅម៉ោង ១០:០០នាទី
- រសៀលម៉ោង ២:០០- ៥:០០នាទី ហើយរយ:ពេលសំរាកគឺចន្លោះពី៣:៤៥ ទៅម៉ោង ៤:០០នាទី

### ប្រការ ៤- ទំនាស់ផលប្រយោជន៍

ក. បុគ្គលិក អ្នកស្ម័គ្រចិត្តនិងអ្នកជំនាញការរបស់មជ្ឈមណ្ឌល ភី ឌី ភី មិនត្រូវប្រើឈ្មោះ មជ្ឈមណ្ឌលដើម្បីរក កំរៃផ្ទាល់ខ្លួន។

ខ. ចំពោះសាច់ញាតិ ដូចជាបងប្អូន ប្តី ប្រពន្ធ មិនអាចធ្វើការនៅក្នុងផ្នែកជាមួយគ្នាបានឡើយ ជាពិសេសផ្នែកហេរិញ្ញវត្ថុ និង រដ្ឋបាល។

គ. ក្នុងករណីប្តី ឬប្រពន្ធជាប្រធានមជ្ឈមណ្ឌលភីឌីភី មិនត្រូវយកបងប្អូន ឬប្រពន្ធ ឬប្តីរបស់ខ្លួនអោយធ្វើការផ្នែកហេរិញ្ញវត្ថុ និង រដ្ឋបាលឡើយ។

ឃ. បុគ្គលិករបស់មជ្ឈមណ្ឌលភីឌីភី មិនអាចធ្វើការដែលទទួលបានប្រាក់បៀវត្សពីរកន្លែងឡើយ ។

ប្រការ ៥- ការលើកទឹកចិត្ត

ក. ការកសាងសមត្ថភាព

បុគ្គលិករបស់មជ្ឈមណ្ឌលភីឌីភី គ្រប់ប្រភេទទទួលបានឱកាសដើម្បីអភិវឌ្ឍន៍ជំនាញស្របតាមការងាររបស់ខ្លួនគ្រប់ៗគ្នា តាមរយៈការផ្តល់អោយជាក្រុម ឬជាបុគ្គលទាំងនៅក្នុងប្រទេស និង ក្រៅប្រទេស។ ចំពោះការកសាងសមត្ថភាពដែលផ្តល់អោយដោយ មជ្ឈមណ្ឌលភីឌីភី ទោះជានៅក្នុងប្រទេស និង ក្រៅប្រទេសគឺត្រឹមរយៈពេល ៦ខែ នឹងមិនត្រូវបានកាត់ប្រាក់ខែឡើយ។ ចំពោះការកសាងសមត្ថភាពណាដែលធ្វើឡើងតាមរយៈបុគ្គលិកជាបុគ្គលដោយផ្ទាល់ ក្នុងការទាក់ទងទៅចូលរៀនវគ្គផ្សេងៗលើសពីរយៈពេលបីខែដោយមិនអាចបំពេញការងារអោយមជ្ឈមណ្ឌល ភីឌីភីបាននោះ នឹងត្រូវកាត់ប្រាក់ខែទាំងស្រុង។

ខ. ការស្វែងរកពិសោធន៍ និង ជំនាញ

បុគ្គលិករបស់មជ្ឈមណ្ឌលភីឌីភី ត្រូវបានលើកទឹកចិត្តអោយធ្វើអ្នកផ្តល់យោបល់ អ្នកផ្តល់ប្រឹក្សា ឬការផ្តល់ជំនាញឬវគ្គបណ្តុះបណ្តាលនានាអោយអង្គការឬវិស័យផ្សេងៗបាន ដែលមិនលើសពី២០ថ្ងៃក្នុងមួយឆ្នាំ។ បើលើសពីរយៈពេលនេះត្រូវបង់អោយមជ្ឈមណ្ឌលភីឌីភី៣០ ភាគរយសំរាប់ថ្ងៃដែលលើស។

**គ. ការធ្វើគំរោងកម្មវិធីពិសេស ឬកម្មវិធីដែលមានរយៈពេលខ្លី**

ការធ្វើគំរោងកម្មវិធីពិសេសឬកម្មវិធីដែលមានរយៈពេលខ្លីលើសពី២០ថ្ងៃក្នុងមួយឆ្នាំដែលទទួលបានកិច្ចព្រមព្រៀងរវាង អង្គការ ឬស្ថាប័ន ដទៃ ជាមួយមជ្ឈមណ្ឌលភីឌីភី នឹងត្រូវលើកទឹកចិត្តអោយបុគ្គលិកធ្វើ តែមជ្ឈមណ្ឌលភីឌីភី នឹងកាត់ ៣០ភាគរយ នៃប្រាក់កំរៃ សំរាប់ទ្រទ្រង់មជ្ឈមណ្ឌលភីឌីភី។

**ប្រការ ៥- <u>ការគោរព</u>**

មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និសន្តិភាពប្រព្រឹត្តិទៅលើបុគ្គលិក, អ្នកស្ម័គ្រចិត្ត និងជំនាញការទាំងអស់ដោយគោរពស្មើភាព និងដោយសេចក្តីថ្លៃថ្នូរ ហើយបុគ្គលិក អ្នកស្ម័គ្រចិត្ត និងជំនាញការ ភី ឌី ភី ប្រព្រឹត្តទៅលើមិត្តរួមការងារ ដូចគ្នាដោយ គោរព និងសេចក្តីថ្លៃថ្នូរក្នុងការប្រាស្រ័យទាក់ទងល្អជាមួយគ្នា ។

**ប្រការ ៦-<u>អកប្បកិរិយាគំរាមកំហែង</u>**

ការវាយតប់ដោយបុគ្គលិក អ្នកស្ម័គ្រចិត្ត ឬជំនាញការផ្សេងៗ ទៅលើបុគ្គលិក អ្នកស្ម័គ្រចិត្តឬជំនាញការណាម្នាក់ក្នុងបរិវេណទីស្នាក់ការមជ្ឈមណ្ឌល ឬនៅទីតាំងដែលខ្លួនកំពុងបំរើការងារអោយមជ្ឈមណ្ឌល បុគ្គលិក អ្នកស្ម័គ្រចិត្ត ឬជំនាញការរូបនោះនឹងត្រូវបណ្តេញចេញពីការងារ ។

**ប្រការ ៧ – <u>ការប្រព្រឹត្ត</u>**

ការប្រព្រឹត្តដោយកាយវិការ/ពាក្យសំដីរបស់បុគ្គលិក អ្នកស្ម័គ្រចិត្ត ឬអ្នកជំនាញការផ្សេងៗ ដែលធ្វើអោយខូចកិត្តិយសរបស់ មជ្ឈមណ្ឌលទោះក្នុងឬក្រៅម៉ោងធ្វើការមិនត្រូវអនុញ្ញាតអោយមានជាដាច់ខាត ។ ប៉ុន្តែបុគ្គលិក អ្នកស្ម័គ្រចិត្ត និងអ្នកជំនាញការរបស់ មជ្ឈមណ្ឌលមានសិទ្ធិបញ្ចេញមតិរិះគន់ជាបុគ្គលឬក្រុមបានដោយសេរីក្នុងពេលប្រជុំប្រចាំខែឬ ប្រជុំប្រចាំឆ្នាំ និងការប្រជុំផ្សេងៗរបស់ មជ្ឈមណ្ឌល ។ ក្នុងនោះរាប់បញ្ចូលទាំងគោលនយោបាយដឹកនាំ គ្រប់គ្រងរបស់ប្រធាន ការចាត់ចែងហិរញ្ញវត្ថុ និងភាពអសកម្មផ្សេងៗ ។

ចំពោះបុគ្គលិក អ្នកស្ម័គ្រចិត្ត ឬអ្នកជំនាញការណាដែលដើរនិយាយបង្ខូចកិត្តិយសមជ្ឈមណ្ឌលក្រៅអង្គប្រជុំនឹងត្រូវបញ្ឈប់ពីការងារជាស្វ័យប្រវត្តិ ។ ក្នុងករណីធ្ងន់ធ្ងរមជ្ឈមណ្ឌលនឹងចាត់វិធានការទៅតាមច្បាប់ ។

## ប្រការ ៨ – ការទទួលខុសត្រូវ

បុគ្គលិក អ្នកស្ម័គ្រចិត្តនិងជំនាញការទាំងអស់ត្រូវតែប្រព្រឹត្តអំពើជាគំរូនៃភាពស្មោះត្រង់និងសេចក្ដីសុចរិតយ៉ាងខ្ពស់ដោយមិនត្រូវរំលោភទៅលើតួនាទី ភារកិច្ចដែលមានចែងក្នុងបំណែងចែកការងារបុគ្គលិករបស់ ភី ឌី ភី ឡើយ។ បុគ្គលិក ភី ឌី ភី មិនអាចផ្ទេរការទទួលខុសត្រូវរបស់ខ្លួនអោយអ្នកដ៏ទៃដោយគ្មានការអនុញ្ញាតពីប្រធានមជ្ឈមណ្ឌលឬពីអង្គប្រជុំរបស់ ភី ឌី ភី ឡើយ ។

## ប្រការ ៩ – ការយាយីដល់ការរំលោភផ្លូវភេទ

សកម្មភាពអាណាចារនិងការបៀតបៀនកេរ្តិ៍ខ្មាសគ្រប់រូបភាពត្រូវហាមឃាត់ដាច់ខាត ។ ក្នុងករណីមានសកម្មភាពបែបនេះ ភី ឌី ភី នឹងចាត់វិធានការតាមច្បាប់។

## ប្រការ ១០ – គ្រឿងញៀនខុសច្បាប់ គ្រឿងញៀនស្រវឹង និងបារី

ភី ឌី ភី ជាកន្លែងមួយគំរូមិនអោយមានប្រើប្រាស់គ្រឿងញៀនខុសច្បាប់ គ្រឿងស្រវឹង និងបារីឡើយ ។ បុគ្គលិកអ្នកស្ម័គ្រចិត្ត ឬអ្នកជំនាញការ ភី ឌី ភី មិនត្រូវជួញដូរឬប្រើប្រាស់គ្រឿងញៀនខុសច្បាប់នានាដូចជាយ៉ាម៉ាយ៉ាបា អាភៀន កញ្ឆា......។ល។ ទោះនៅក្នុងឬក្រៅបរិវេណរបស់ ភី ឌី ភី ។ ការរំលោភបំពានលក្ខខ័ណ្ឌនេះត្រូវផ្ដន្ទាទោសដោយបញ្ឈប់ពីការងារភ្លាម ហើយមិនត្រូវបានផ្ដល់ប្រាក់សោធននិវត្តន៍ ឬប្រាក់កំរៃអ្វីទាំងអស់ ។

## ប្រការ ១១ – ការផ្សព្វផ្សាយពត៌មាន

សេចក្ដីថ្លែងការណ៍ទូទៅក្នុងនាមមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាពអាចធ្វើឡើងមានតែប្រធានមជ្ឈមណ្ឌលស្នាក់ការកណ្ដាលដែលមានទីតាំងនៅភ្នំពេញតែប៉ុណ្ណោះ រឺក៏អ្នកដែលត្រូវបានតែងតាំងឡើងជាលាយលក្ខណ៏អក្សរដោយប្រធានមជ្ឈមណ្ឌលស្នាក់ការកណ្ដាល ។

## ប្រការ ១២ – ប្រាក់ឧបត្ថម្ភចូលឆ្នាំ

មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព ផ្តល់ប្រាក់ឧបត្ថម្ភមួយដងក្នុង១ឆ្នាំនៅពេលពិធីបុណ្យចូលឆ្នាំខ្មែរ ប្រាក់ឧបត្ថម្ភនេះស្មើនឹង ៣០ ដុល្លារ នៃប្រាក់ខែ ហើយនឹងត្រូវបានគណនាតាមប្រព័ន្ធសមាមាត្រជាមូលដ្ឋាន។ ចំនុចនេះអាចប្រែប្រួលដោយយោងទៅលើស្ថានភាពថវិការបស់មជ្ឈមណ្ឌលភីឌីភី។

## ប្រការ ១៣- សោហ៊ុយបេសកកម្ម

**ក.អាហារនិងការស្នាក់នៅ:** បុគ្គលិកស្នាក់ការកណ្តាលចុះបំពេញបេសកកម្មទៅតាមបណ្តាខេត្ត/ក្រុងត្រូវទទួលបាន ១០ ដុល្លារក្នុង ១ ថ្ងៃលើថ្លៃអាហារ និង ១៥ ដុល្លារលើថ្លៃស្នាក់នៅក្នុង មួយយប់។ ចំពោះបុគ្គលិកសាខាខេត្ត/ក្រុងឡើងមកភ្នំពេញត្រូវទទួលបាន ១០ ដុល្លារក្នុង ១ ថ្ងៃលើថ្លៃអាហារ និង ១២ ដុល្លារលើថ្លៃស្នាក់នៅក្នុងមួយយប់។

**ខ. ការធ្វើដំណើរក្នុងប្រទេស:** ការធ្វើដំណើរក្នុប្រទេសត្រូវធ្វើទៅតាមអត្រាតម្លៃដែលបានកំណត់មួយជាក់ជាក់ ដែលធ្វើបច្ចុប្បន្នភាពរៀងរាល់ពីរឆ្នាំម្តង។

អាត្រាតម្លៃនេះត្រូវបានកំណត់ទៅតាមបណ្តាខេត្តនីមួយៗដូចខាងក្រោម :

| | |
|---|---|
| ១- ភ្នំពេញ-កណ្តាល | ៣ ដុល្លារ |
| ២- ភ្នំពេញ- តាកែវ | ៦ ដុល្លារ |
| ៣- ភ្នំពេញ-កំពត | ១០ ដុល្លារ |
| ៤- ភ្នំពេញ-ក្រុងព្រះសីហនុ | ១២ ដុល្លារ |
| ៥- ភ្នំពេញ-កោះកុង | ២៥ ដុល្លារ |
| ៦- ភ្នំពេញ-កំពង់ស្ពឺ | ៤ ដុល្លារ |
| ៧- ភ្នំពេញ- កំពង់ឆ្នាំង | ៧ ដុល្លារ |
| ៨- ភ្នំពេញ-ពោធិសាត់ | ១០ ដុល្លារ |
| ៩- ភ្នំពេញ-បាត់ដំបង | ១២ ដុល្លារ |
| ១០- ភ្នំពេញ- បន្ទាយមានជ័យ | ១៥ ដុល្លារ |
| ១១- ភ្នំពេញ-សៀមរាប | ១២ ដុល្លារ |
| ១២- ភ្នំពេញ- កំពង់ធំ | ១១ ដុល្លារ |
| ១៣- ភ្នំពេញ- កំពង់ចាម | ៨ ដុល្លារ |
| ១៤- ភ្នំពេញ- ស្វាយរៀង | ១៥ ដុល្លារ |
| ១៥- ភ្នំពេញ- ព្រៃវែង | ៩ ដុល្លារ |
| ១៦- ភ្នំពេញ-ក្រចេះ | ១៧ ដុល្លារ |
| ១៧- ភ្នំពេញ- រតនគិរី | ៥០ដុល្លារ |

១៨- ភ្នំពេញ- ឧត្តរមានជ័យ ៤០ ដុល្លារ

១៩- ភ្នំពេញ-ព្រះវិហារ ៤០ ដុល្លារ

២០- ភ្នំពេញ- មណ្ឌលគិរី ៤៥ ដុល្លារ

២១- ភ្នំពេញ- ប៉ៃលិន ៤០ ដុល្លារ

២២- ភ្នំពេញ- កែប ១៣ ដុល្លារ

២៣- ភ្នំពេញ-ស្ទឹងត្រែង ៣៥ ដុល្លារ

ការធ្វើដំណើរនៅក្នុងមូលដ្ឋាន សំរាប់ពីទីរួមខេត្តទៅកាន់តំបន់គោលដៅនៅតាមភូមិ ឬពីសណ្ឋាគារទៅកាន់កន្លែង ធ្វើសកម្មភាព ឬកន្លែងប្រជុំគឺ ៥ ដុល្លារក្នុងមួយថ្ងៃ។ ចំពោះចម្ងាយផ្លូវដែលលើសពី ៥ គ.ម ការចំណាយលើការធ្វើ ដំណើរត្រូវទូរទាត់តាមការចំណាយជាក់ស្តែង។ ចំពោះបុគ្គលិកខេត្តដែលឡើងមកភ្នំពេញ នឹងត្រូវផ្តល់ជូន៣ដុល្លារសំរាប់ការធ្វើដំណើរក្នុងរាជធានី ក្នុងមួយថ្ងៃ។

**គ. អាហារ នឹងត្រូវបានកំណត់ទៅតាមពេលវេលាចេញដំណើរ និង ការមកដល់ការិយាល័យ**

**១.ការចេញដំណើរៈ** បុគ្គលិកដែលចេញ ដំណើរពីការិយាល័យចាប់ពីម៉ោង ១០:០០ ព្រឹក ត្រូវចេញថ្លៃអាហារជូនបីពេល ចំណែកបុគ្គលិកដែលចេញដំណើរក្រោយម៉ោង១០ ទៅម៉ោង១:០០ ត្រូវជូនអាហារពីរពេល។ ចំពោះការចេញដំណើរ ក្រោយម៉ោង១:០០ នឹងត្រូវជូនថ្លៃអាហារតែមួយពេលប៉ុណ្ណោះ។

**២.ការត្រឡប់មកវិញៈ** ការមកដល់ការិយាល័យត្រឹមម៉ោង ១០:០០ ព្រឹក ត្រូវផ្តល់ជូនតែថ្លៃអាហារពេលព្រឹកមួយពេល ហើយការមកដល់ការិយាល័យក្រោយម៉ោង១:០០ រសៀល ត្រូវផ្តល់ជូនអាហារពីរពេល។ ក្នុងករណីមកដល់ការិយាល័យក្រោយម៉ោង៥:០០ ល្ងាចត្រូវផ្តល់ជូនអាហារបីពេល។

**៣. ការបែងចែកថ្លៃអាហារសំរាប់ពេលនីមួយៗ**

- ពេលព្រឹកៈ ៣ ដុល្លារ
- ពេលថ្ងៃត្រង់ៈ ៣.៥ ដុល្លារ
- ពេលល្ងាច :៣.៥ ដុល្លារ

**ឃ. ការទូទាត់ៈ** បុគ្គលិកចុះបំពេញបេសកកម្មត្រូវប្រគល់របាយការណ៍សកម្មភាពជូនការិយាល័យរដ្ឋបាល និងរបាយការណ៍ថវិកាជូនគណនេយ្យកររបស់មជ្ឈមណ្ឌល មិនអោយលើសពី ៣ថ្ងៃ បន្ទាប់ពីត្រឡប់ពីបំពេញបេសកកម្ម ។ លើកលែងតែវិក័យប័ត្រធ្វើដំណើរ ស្នាក់នៅ និង អាហារមិនត្រូវបានទូរទាត់ឡើយ។ ការចុះបំពេញបេសកកម្មក្នុងប្រទេសរបស់បុគ្គលិក ត្រូវតែមានលិខិតបញ្ជាបេសកកម្ម របស់ភី ឌី ភី។

**ប្រការៈ ១៤–**<u>**នាឡិកាចុះវត្តមាន**</u>

បុគ្គលិករបស់ ភី ឌី ភី ត្រូវបានទទួលប្រាក់បៀវវត្សទៅតាមឋានៈ ការទទួលខុសត្រូវ បទពិសោធន៍ និងជំនាញពាក់ព័ន្ធនឹងការងារ ។ តារាងបៀវវត្សមានកំនត់នៅក្នុងគោលការណ៍គណនេយ្យ ។

## ប្រការ ១៥– ការតំលើងប្រាក់បៀវវត្ស

ការតំលើងប្រាក់ខែបុគ្គលិកនឹងត្រូវគិតទៅតាមឋានៈ និងទំហំការងារបច្ចុប្បន្នរបស់បុគ្គលិក ដែលមានដូចខាងក្រោម :

- ប្រធាន ១២ % នៃប្រាក់ខែជាមូលដ្ឋាន
- ប្រធានផ្នែកគ្រប់ផ្នែកនឹងទទួលបាន ១២% នៃប្រាក់ខែមូលដ្ឋាន
- បុគ្គលិកស្នាក់កណ្តាល និង បុគ្គលិកជំនួយការកម្មវិធី ១៣ % នៃប្រាក់ខែមូលដ្ឋាន
- ប្រធានសាខាខេត្ត / ក្រុង ១៣% នៃប្រាក់ខែជាមូលដ្ឋាន
- បុគ្គលិកសាខាខេត្ត/ក្រុង និង បុគ្គលិកដទៃទៀត ១៥% នៃប្រាក់ខែមូលដ្ឋាន

ការតំឡើងប្រាក់ខែបុគ្គលិកធ្វើឡើងតាមខួបនៃឆ្នាំនីមួយៗ ។ ការតម្លើងប្រាក់ខែនេះអាចធ្វើទៅបានអាស្រ័យលើមូលនិធិ ឬ ប្រាក់ចំណូលដែលទទួលបានប្រចាំឆ្នាំនីមួយៗ។

## ប្រការ ១៦– ការបង់វិភាគទានរបស់បុគ្គលិក

បុគ្គលិកដែលទទួលបានប្រាក់បៀវវត្សចាប់ពី២០០១ ដុល្លារឡើងទៅត្រូវបង់ប្រាក់វិភាគទាន ៥ដុល្លារក្នុងមួយខែ ។ បុគ្គលិកដែលទទួលបានប្រាក់បៀវវត្សចាប់ពី១០០ ទៅ ២០០ដុល្លារ ត្រូវបង់ ៣ដុល្លារក្នុង មួយខែ ។ ដោយឡែក បុគ្គលិកដែលទទួលបានប្រាក់បៀវវត្សក្រោម១០០ ដុល្លារត្រូវបង់ ១ដុល្លារក្នុងមួយខែ។ ថវិកានេះបានត្រូវរក្សា ទុកដោយគណ នេយ្យករ។ ទឹកប្រាក់ទទួល បានពីការបង់ វិភាគទាន គណនេយ្យកររបស់មជ្ឈមណ្ឌលត្រូវមាន គោលការណ៍ ត្រឹមត្រូវ ។ ប្រាក់បង់វិភាគទាន នេះប្រើប្រាស់ពេល បុគ្គលិករបស់ ភី ឌី ភី បានបញ្ចប់ ឬបញ្ឈប់។

## ប្រការ ១៧– និតិវិធីអនុវត្តនៅពេលបុគ្គលិកមានជម្ងឺ

នៅពេលបុគ្គលិកមានជំងឺ គេត្រូវតែស្វែងរកការព្យាបាលតាមគ្លីនិក ឬមន្ទីរពេទ្យសាធារណៈ ។

- បើបុគ្គលិកឈឺធ្ងន់មិនអាចមកធ្វើការបាន ត្រូវផ្តល់ដំណឹងជូនអ្នកគ្រប់គ្រងជាបន្ទាន់ ។
- ទិញប័ណ្ណធានារ៉ាប់រងសុខភាពនិងគ្រោះថ្នាក់ប្រចាំឆ្នាំ។

## ប្រការ ១៨– អត្ថប្រយោជន៍

ក- ថ្លៃធ្វើដំណើរប្រចាំខែ

១- ប្រធាន : ៦០

២- មន្ត្រីកម្មវិធី: ៣០

៣- គណនេយ្យករៈ ១៥

៤- ប្រធានសាខាខេត្តៈ២០

៥- ជំនួយការកម្មវិធី និង គ្រូបង្គោលសាខាខេត្តៈ ១៥

៦- រដ្ឋបាល ៈ១៥

៧- ជំនួយការគណនេយ្យៈ១៥

៨- អ្នករត់សំបុត្រៈ២០

ខ- ជារៀងរាល់ខែ បុគ្គលិកនឹងទទួលបានប្រាក់កំរៃសុខភាពចំនួន ១០ដុល្លារ ។

គ-ប្រាក់សំរាប់សេវាទូរស័ព្ទ

ប្រធានមជ្ឈមណ្ឌលស្នាក់ការកណ្តាលទទួលប្រាក់សេវាទូរស័ព្ទជាមធ្យម ៤០ ដុល្លារក្នុង១ខែ។ រីឯបុគ្គលដែលជាប្រធានផ្នែកទទួលប្រាក់សេវាទូរស័ព្ទបាន ១០ ដុល្លាក្នុង១ខែ និងប្រធានសាខាខេត្ត /ក្រុងទទួលបាក់សេវាទូរស័ព្ទបាន ១០ ដុល្លាក្នុង១ខែ។ គ្រូបង្គោលនិង ជំនួយការនឹងផ្តល់ជូន ៥ដុល្លារ ក្នុងមួយខែ។

ប្រការ១៨ នេះ អាចប្រែប្រួលបានដោយយោងទៅលើទំហំសកម្មភាព និងស្ថានភាព ថវិការបស់មជ្ឈមណ្ឌលភីឌីភី។

## ប្រការ ១៩ – ការបាត់បង់សមត្ថភាពពលកម្មជាអចិន្ត្រៃយ៍ និងមរណភាព

មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព រ៉ាប់រងគ្រោះថ្នាក់ដល់បុគ្គលិករបស់ខ្លួនក្នុងពេលបំពេញ ការងារអោយមជ្ឈមណ្ឌល។ ចំនួនទឹកប្រាក់សរុប ១ ០០០ដុល្លារសហរដ្ឋអាមេរិក ( មួយពាន់ដុល្លារសហរដ្ឋអាមេរិក) ត្រូវបានផ្តល់ជូនអោយបុគ្គលិក ឬក្រុមគ្រួសារបុគ្គលិកក្នុងករណីស្លាប់ ឬ បាត់បង់សមត្ថភាពពលកម្មជាអចិន្ត្រៃយ៍ ។

បាត់បង់សមត្ថភាពពលកម្មរួមមាន ៈ

- បាត់បង់ភ្នែកទាំងសងខាង
- ត្រូវថ្លង់ទាំងស្រុង
- បាត់បង់អវយវៈទាំងអស់
- មិនអាចកំរើកខ្លួនបានទាំងស្រុង

គោលនយោបាយនេះគឺមិនគ្របដណ្តប់ទៅដល់ការពិការដែលមានពីមុនចូលមកធ្វើការនៅមជ្ឈមណ្ឌលនោះទេ ។

មជ្ឈមណ្ឌលនឹងមិនបង់អោយបុគ្គលិកទទួលមរណភាព ដែលក្រោយពីការស៊ើបអង្កេតដឹងថាជាឧក្រិដ្ឋជននោះឡើយ ។

## ប្រការ ២០ – ការឈប់សំរាកប្រចាំឆ្នាំ

បុគ្គលិកមានសិទ្ធិឈប់សំរាកប្រចាំឆ្នាំជាអតិប្បរមា ២១ថ្ងៃ ដោយមិនរួមបញ្ចូលថ្ងៃឈប់សំរាកបុណ្យជាតិ -អន្តរជាតិនិងថ្ងៃសៅរ៍-អាទិត្យឡើយ ។ ការសុំច្បាប់ឈប់សំរាកមិនអាចអនុញ្ញាតអោយបុគ្គលិកលើសពី ២នាក់ ក្នុងពេលតែមួយឡើយ។ បុគ្គលិកដែលពាក់ព័ន្ធនឹងការងារបន្ទាន់នានារបស់មជ្ឈមណ្ឌលមិនត្រូវបានអនុញ្ញាតអោយឈប់ឡើយ លុះត្រាតែការងារនោះបានចប់សព្វគ្រប់ទើបអនុញ្ញាតអោយឈប់សំរាកបាន ។

## ប្រការ ២១- ការឈប់សំរាកមាតុភាព

បុគ្គលិកមានសិទ្ធិទទួលការឈប់លំហែមាតុភាពរយៈពេល ៩០ថ្ងៃ ដោយរក្សាប្រាក់បៀវត្សដដែល និង ទទួលបានប្រាក់ឧបត្ថម្ភ ៥០ដុល្លារសហរដ្ឋអាមេរិក ចំពោះបុគ្គលិកដែលបានធ្វើការបំរើមជ្ឈមណ្ឌលបាន១ឆ្នាំរៀងមក។

## ប្រការ ២២- ការឈប់បិតុភាព

បុគ្គលិកមានសិទ្ធិឈប់សំរាកបិតុភាពរយៈពេល ៥ថ្ងៃ ។

## ប្រការ ២៣- ការឈប់សំរាកពេលរៀបអាពាហ៍ពិពាហ៍

ច្បាប់ឈប់សំរាករៀបអាពាហ៍ពិពាហ៍រយៈពេល ១សប្តាហ៍ ដោយមិនកាត់ប្រាក់ខែបុគ្គលិកដែលរៀប-អាពាហ៍ពិពាហ៍នោះឡើយ ។ បុគ្គលិកដែលរៀបអាពាហ៏ពិពាហ៏នឹងទទួលបានប្រាក់ឧបត្ថម្ភ ៣០ដុល្លារ សំរាប់បុគ្គលិកស្នាក់ការកណ្តាល និង ប្រធានសាខាខេត្ត/ក្រុង ហើយនិងទទួលបាន ២០ដុល្លារ សំរាប់បុគ្គលិកកម្មវិធីតាមខេត្ត/ក្រុង ។

## ប្រការ ២៤- អវត្តមានគ្មានច្បាប់

បុគ្គលិកអវត្តមានដោយគ្មានមូលហេតុលើកទី១ -ទី២ព្រមានដោយផ្ទាល់មាត់ឬលាយលក្ខណ៏អក្សរ ចាប់ពីលើកទី៣ឡើងទៅត្រូវកាត់ប្រាក់ខែ ១ពេល ២ ដុល្លារ។ សំរាប់ការយឺតយ៉ាវម្តងម្កាល ពេលព្រឹកចាប់គិតពីម៉ោង ៩:០០នាទីព្រឹក ល្ងាចចាប់គិតពីម៉ោង ៣:០០នាទីរសៀល ។ ការការយឺតយ៉ាវថ្ងៃ ដដែល១ រៀងរាល់សប្តាហ៍មិនត្រូវ បានអនុញ្ញាតជាដាច់ខាត។

## ប្រការ ២៥- ការឈប់សំរាកដោយសេចក្តីមេត្តាធម៌

ការឈប់សំរាកដោយក្តីមេត្តាធម៌ត្រូវបានអនុញ្ញាតមួយសប្តាហ៍ ដោយរក្សាប្រាក់ខែពេញនឹងត្រូវបានផ្តល់ជូនបុគ្គលិកក្នុងករណីសាច់ញ្ញាតិជិតស្និទ្ធមានជំងឺធ្ងន់ធ្ងរឺមរណៈភាព ។

## ប្រការ ២៦-ការជ្រើសរើសបុគ្គលិក

ការិយាល័យរដ្ឋបាលប្រកាសជូនដំណឹងជ្រើសរើសបុគ្គលិកជាសាធារណៈហើយបេក្ខជនត្រូវដាក់ពាក្យសុំសំភាសន៍និងឆ្លងកាត់ការសំភាសន៍ត្រឹមត្រូវ បន្ទាប់ពីសំភាសន៍រួចត្រូវឆ្លងការប្រជុំសំរេចពីគណកម្មាធិការប្រតិបត្តិរបស់មជ្ឈមណ្ឌល ។

## ប្រការ ២៧ – ការបណ្តុះបណ្តាលជំនាញ

បុគ្គលិកគ្រប់រូបត្រូវបានលើកទឹកចិត្តក្នុងការបណ្តុះបណ្តាលជំនាញ និងបង្កើនសមត្ថភាពរបស់ខ្លួនតាមរយៈការចូលរួមវគ្គសិក្ខាសាលា ការប្រជុំ និងវគ្គសិក្សាផ្សេងៗទាំងក្នុង និងក្រៅប្រទេស ។ វគ្គសិក្សាទាំងនោះត្រូវតែពាក់ព័ន្ធទៅនឹងមុខងារ និងភារកិច្ចទទួលខុសត្រូវរបស់ខ្លួន ។ បុគ្គលិកដែលត្រូវបានមជ្ឈមណ្ឌលបញ្ជូនអោយទៅរៀន ទោះក្នុងឬក្រៅប្រទេសក្នុងរយៈពេលក្រោម ៣ខែ ត្រូវរក្សាប្រាក់ខែដដែលចាប់ពី ៣ខែ ឡើងទៅផ្តល់ប្រាក់បៀវត្សជូន៣ខែ ។

## ប្រការ ២៨ – ការបញ្ឈប់ពីការងារនិងការបញ្ចប់កិច្ចសន្យា

ការបញ្ឈប់ពីការងារចំពោះបុគ្គលិកត្រូវមានការអនុម័តពីគណកម្មាធិការប្រតិបត្តិរបស់ភី ឌី ភី។ បុគ្គលិកដែលបញ្ចប់ដោយកិច្ចសន្យាអ្នកគ្រប់គ្រងនឹងផ្តល់ដំណឹងជូនមុន ១ខែ ។ រាល់ការប្រព្រឹត្តខុសឆ្គងរបស់ បុគ្គលិកនឹងត្រូវបញ្ឈប់បន្ទាប់ពីធ្វើសេចក្តីសំរេចដោយគណកម្មាធិការប្រតិបត្តិរបស់ ភី ឌី ភី។ ការបញ្ឈប់ដោយសារមានកំហុសឆ្គង និង ការដាក់ពាក្យសុំឈប់ពីការការងារដែលមានរយៈពេលតិចជាងមួយខែនឹងមិនត្រូវបានផ្តល់ប្រាក់បំណាច់ជូនឡើយ។

ការផ្តល់ប្រាក់បំណាច់ត្រូវបានគិតដូចតទៅ :

១ - រយៈពេលបំរើការងារចាប់ពី ៣ឆ្នាំឡើងទៅទទួលបានប្រាក់ឧបត្ថម្ភ ១ខែ នៃប្រាក់ខែចុងក្រោយ

២- រយៈពេលបំរើការងារចាប់ពី ៦ឆ្នាំឡើងទៅទទួលបានប្រាក់ឧបត្ថម្ភ ២ខែ នៃប្រាក់ខែចុងក្រោយ

៣- រយៈពេលបំរើការងារចាប់ពី ៩ឆ្នាំឡើងទៅទទួលបានប្រាក់ឧបត្ថម្ភ ៣ខែ នៃប្រាក់ខែចុងក្រោយ

## ប្រការ ២៩ – អវសានបញ្ញត្តិ

បុគ្គលិកគ្រប់រូបរបស់ ភី ឌី ភី តំរូវអោយគោរពតាមគោលនយោបាយនេះ ។ កំហុសទាំងឡាយណាដែលកើតមានឡើងដោយហេតុថាមិនដឹងមិនឮចំពោះគោលនយោបាយនេះ មិនអាចអត់អោនទោសបានឡើយ ។ រាល់ការអនុវត្តន៏ ផ្ទុយពីគោលនយេបាយនេះចាត់ទុកជាមោឃៈ ។

ភ្នំពេញ ថ្ងៃទី ..............ខែ .................ឆ្នាំ ២០១១

ភ្នំពេញ ថ្ងៃទី ..............ខែ .................ឆ្នាំ ២០១១ **ប្រធាន**

**ជ.គណម្មាធិការនាយក**

**ប្រធាន**

**យង់ គិមអេង**

**ខឿ ស្រីនួច**